អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ការបើកប្រទេសឡើងវិញនឹងជួយស្តារកំណើនសេដ្ឋកិច្ចនៅឆ្នាំក្រោយកាន់តែប្រសើរ
- ធនាគារជាតិបានជូនដំណឹងថា កម្ពុជាមានទុនបម្រុងអន្តរជាតិសរុបចំនួន ២១ប៊ីលានដុល្លារអាមេរិក
- អគ្គនាយកដ្ឋានពន្ធដារផ្សព្វផ្សាយដល់ធុរកិច្ចម៉ាឡេស៊ីនៅកម្ពុជា ពីការលុបបំបាត់ការយកពន្ធត្រួតគ្នា
- ក្រសួងដាក់ឱ្យដំណើរការ គេហទំព័រលក់ផលិតផលរបស់សហគ្រាសធុនតូច និងមធ្យម
- ពាណិជ្ជកម្មកម្ពុជា-សហរដ្ឋអាមេរិក សម្រេចបានជិត ៦ពាន់លានដុល្លារ នៅ៩ខែដំបូងឆ្នាំ២០២១
- រយៈពេល០៩ខែដំបូងឆ្នាំ២០២១ ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងកូរ៉េខាងត្បូងធ្លាក់ចុះជាង១៨%
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍បញ្ជាក់ថា រុស្ស៊ីនឹងរៀបចំឱ្យពលរដ្ឋមកលេងកម្ពុជាក្នុងពេលឆាប់ៗនេះ
- ការនាំចេញជ្វូងប្រេងក្នុងឆ្នាំនេះធ្លាក់ចុះតិចតួច ប៉ុន្តែតម្លៃនៅតែខ្ពស់
- មធ្យោបាយលើកទឹកចិត្តពន្ធនៅតាមបណ្តាប្រទេសសមាជិកអាស៊ានដើម្បីទាក់ទាញវិនិយោគ
- ពាណិជ្ជកម្មក្រៅប្រទេសនៅទីក្រុងហូជីមិញមានការងើបឡើងវិញយ៉ាងខ្លាំង
- សសរស្តម្ភចំនួន៦របស់វៀតណាម ដើម្បីស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ១៩
- ធនាគារសហរដ្ឋអាមេរិកគ្រោងនឹងធ្វើការខ្ចី ១,០២ទ្រីលានដុល្លារ សម្រាប់ត្រីមាសទី៤
- សេដ្ឋវិទូព្រមានថាសេដ្ឋកិច្ចចិន បានបង្ហាញសញ្ញាស្ថិរតាអតិផរណា (Stagflation)
- តម្លៃបន្លែឡើងខ្លាំង លើសតម្លៃសាច់ជ្រូក បង្កក្តីបារម្ភដល់ពលរដ្ឋចិន

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី២ ខែវិច្ឆិកា ឆ្នាំ២០២១ លេខ ៖ ៩២

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការបើកប្រទេសឡើងវិញនឹងជួយស្តារកំណើនសេដ្ឋកិច្ច នៅឆ្នាំក្រោយកាន់តែប្រសើរ



*(រូបភាព៖ ស៊ិនហួរ)*

សេដ្ឋកិច្ចកម្ពុជា នឹងមានភាពល្អប្រសើរឡើងវិញលើគ្រប់វិស័យ ក្រោយការប្រកាសបើកប្រទេសឡើងវិញ។ ប្រធានសមាគមធនាគារនៅកម្ពុជា និងជាប្រធាននាយកប្រតិបត្តិធនាគារអេស៊ីលីដា បានចាត់ទុកការសម្រេចនេះគឺត្រឹមត្រូវ និងជាអ្វី ដែលវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ រួមជាមួយវិស័យនានាទន្ទឹងរង់ចាំ។ ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ជឿជាក់ថាសេដ្ឋកិច្ចកម្ពុជានៅចុងឆ្នាំ២០២១ នឹងលូតលាស់ទៅរកប្រក្រតីភាពឡើងវិញ ប្រសិនបើគ្មានការផ្ទុះការឆ្លងជំងឺកូវីដ-១៩ ប្រភេទថ្មីណាមួយកើតឡើង។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានត្រៀមខ្លួនជាស្រេច ក្នុងការផ្តល់កម្ចីជូនអតិថិជនដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាស្តារ និងជំរុញកំណើនសេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិឱ្យមានភាពប្រសើរឡើង។

នាពិធីបិទយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនកុមារអាយុ៦ឆ្នាំ និងបើកយុទ្ធនាការចាក់វ៉ាក់សាំងជូនកុមារអាយុ៥ឆ្នាំ ប្រមុខរាជរដ្ឋាភិបាល ក៏បានប្រកាសបើកដំណើរសកម្មភាពសង្គម និងសេដ្ឋកិច្ចលើគ្រប់វិស័យឡើងវិញ ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ តទៅ បន្ទាប់ពីមើលឃើញពីតួលេខអ្នកឆ្លងជំងឺកូវីដ-១៩ នៅកម្ពុជាមានការថយចុះ និងចំនួនអ្នកបានចាក់វ៉ាក់សាំងមានកំណើនខ្ពស់។ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងមានកំណើនក្នុងរង្វង់២,៦% នៅឆ្នាំ២០២១ ដែលកំណើននេះរំពឹងមានការចូលរួមចំណែកយ៉ាងធំពីវិស័យទេសចរណ៍ផ្ទៃក្នុង។ តាមការព្យាករចុងក្រោយរបស់ធនាគារពិភពលោក បានបន្ទាបការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ២០២១ ពី៤% មកនៅត្រឹម២,២% ខណៈធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ក៏បានទម្លាក់ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជាមកនៅត្រឹម១,៩%នៅឆ្នាំនេះ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០២១*

### ធនាគារជាតិបានជូនដំណឹងថា កម្ពុជាមានទុនបម្រុងអន្តរជាតិសរុបចំនួន ២១ប៊ីលានដុល្លារសហរដ្ឋអាមេរិក



*ធនាគារជាតិនៃកម្ពុជា (រូបថតដោយ៖ ជួ សុគន្ធា )*

ធនាគារជាតិនៃកម្ពុជា (NBC) បានលើកឡើងថា ទុនបម្រុងអន្តរជាតិរបស់កម្ពុជាកើនឡើងដល់ ២១ប៊ីលានដុល្លារ ដែលមានកម្រិតខ្ពស់ជាងកម្រិតអប្បបរមាដែលតម្រូវឱ្យមានសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ។ គួររំលឹកថា កាលពីឆ្នាំ២០២០ ទុនបម្រុងអន្តរជាតិរបស់កម្ពុជាមានចំនួន ២១,៣៣ប៊ីលានដុល្លារ កើនឡើងជាមធ្យមប្រមាណជា ២០,២៥% ក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ២០០១ ដែលមានត្រឹមតែ ៦៩៧លានដុល្លារប៉ុណ្ណោះ។ ទោះយ៉ាងណាទុនបម្រុងអន្តរជាតិរបស់កម្ពុជាក្នុងអំលុងពេលប៉ុន្មានខែនេះមានភាពប្រែប្រួលមិនទៀងទាត់ ដែលមានកម្រិតទាបចាប់ពីខែកញ្ញា ឆ្នាំ២០២០ ដល់ខែសីហា ឆ្នាំ២០២១ គឺធ្លាក់ចុះដល់ ២០,១ប៊ីលានដុល្លារ នៅក្នុងខែសីហា។ ធនាគារជាតិនៃកម្ពុជាបានបែងចែកទុនបម្រុងអន្តរជាតិសម្រាប់វិនិយោគលើសេដ្ឋកិច្ច សង្គម និងអភិបាលកិច្ចចម្រុះ (Economic, Social, and Corporate Governance«ESG») និងបញ្ចូល ESG ទៅក្នុងសៀវភៅណែនាំស្តីពីការវិនិយោគរបស់ខ្លួន។ ទន្ទឹមនឹងនេះធនាគារជាតិបានចូលរួមជំរុញប្រព័ន្ធសេដ្ឋកិច្ចឌីជីថល ដោយបង្កើតកម្មវិធីបាគង ដែលជាកាបូបលុយអេឡិចត្រូនិច។ កាបូបលុយបាគងអាចប្រើសម្រាប់ការទូទាត់ក្នុងស្រុក និងឆ្លងដែន ដើម្បីជួយពង្រឹងសមាហរណកម្មក្នុងតំបន់។

លើសពីនោះធនាគារជាតិនៃកម្ពុជាបានបំពេញតួនាទីរបស់ខ្លួននៅក្នុងការគ្រប់គ្រងល្បឿន ឬកំណើននៃកម្ចីឥណទានតាមរយៈការកំណត់លក្ខខណ្ឌនៅក្នុងការប្រើប្រាស់ទុនបម្រុង។ ធនាគារជាតិបានកំណត់លក្ខខណ្ឌ និងអត្រាការប្រាក់លើទុនបម្រុងសម្រាប់រូបិយបណ្ណក្នុងស្រុក និងរូបិយបណ្ណបរទេសខុសពីគ្នា ជាពិសេសលុយដុល្លារ។ លក្ខខណ្ឌសម្រាប់ទុនបម្រុងជារូបិយបណ្ណបរទេសត្រូវបានកម្រិតដល់ទៅ ១២,៥% ចំណែកឯលក្ខខណ្ឌសម្រាប់ទុនបម្រុងជារូបិយបណ្ណជាតិមានត្រឹមតែ ៨% ប៉ុណ្ណោះ។ បន្ថែមពីនោះ ធនាគារជាតិបានកំណត់អត្រាការប្រាក់លើទុនបម្រុងអន្តរជាតិ ៤,៥% និងមិនយកការប្រាក់លើទុនបម្រុងជាប្រាក់រៀលឡើយ៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ Khmer Times ចេញផ្សាយថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១*

## អគ្គនាយកដ្ឋានពន្ធដារ ផ្សព្វផ្សាយដល់ធុរកិច្ចម៉ាឡេស៊ីនៅកម្ពុជា ពីការលុបបំបាត់ការយកពន្ធត្រួតគ្នា




*ដោយ freshnews*

អគ្គនាយកដ្ឋានពន្ធដារ បានសហការជាមួយសភាពាណិជ្ជកម្មម៉ាឡេស៊ីនៅកម្ពុជា រៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយបន្ថែមអំពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេសពន្ធ និងការចៀសវាងពន្ធ(Double Taxation Agreement-DTA ) កម្ពុជា-ម៉ាឡេស៊ី ជូនក្រុមហ៊ុនម៉ាឡេស៊ីដែលបាននិងកំពុងបណ្តាក់ទុនវិនិយោគនៅកម្ពុជា ដើម្បីយល់ដឹងកាន់តែច្បាស់អំពីអត្ថប្រយោជន៍នានាក្រោមDTA ក៏ដូចជានីតិវិធីដើម្បីទទួលបានអត្ថប្រយោជន៍ទាំងនោះ។

សិក្ខាសាលានេះបានរៀបចំឡើង នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១នេះ តាមប្រព័ន្ធវីដេអូ ដោយមានការចូលរួមពី លោក គង់ វិបុស រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោក Eldeen

Hussaini Mohd Hashim ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា មន្ត្រីជំនាញ និងតំណាងសហគ្រាសដែលជាសភាពាណិជ្ជកម្មម៉ាឡេស៊ីប្រចាំនៅកម្ពុជា និងតំណាងសហគ្រាសផ្សេងទៀតប្រមាណ៥០០នាក់។

អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានថ្លែងថា ទោះបីជាកម្ពុជាស្ថិតក្នុងស្ថានភាពនៃការរីករាលនៃជំងឺកូវីដ១៩ និងបានផ្តល់អត្ថប្រយោជន៍ក្រោមDTA ក៏ដោយ ក៏កម្ពុជានៅតែរក្សាបាននូវកំណើនក្នុងការប្រមូលពន្ធតាមរយៈការហូរចូលបន្ថែមនៃវិនិយោគបរទេស និងការធ្វើទំនើបកម្មប្រព័ន្ធប្រកាសពន្ធតាមអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ។ ជាពិសេសបច្ចុប្បន្នអ្នកស្នើសុំអត្ថប្រយោជន៍ក្រោមDTA ក៏អាចដាក់ពាក្យស្នើសុំអត្ថប្រយោជន៍នេះតាមអនឡាញបានផងដែរ។ ឆ្នាំ២០២១នេះ ជាឆ្នាំដំបូងដែលកិច្ចព្រមព្រៀង DTA កម្ពុជា-ម៉ាឡេស៊ី មានប្រសិទ្ធភាពសម្រាប់អនុវត្ត ក្រោយបានចុះហត្ថលេខាកាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១*

## ក្រសួងដាក់ឱ្យដំណើរការ គេហទំព័រលក់ផលិតផលរបស់សហគ្រាសធុនតូច និងមធ្យម ជួយអភិវឌ្ឍគុណភាពផលិតផល ស្របតាមស្តង់ដារកម្ពុជា



*ដោយ freshnew*

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានដាក់ឱ្យដំណើរការជាផ្លូវការ «**គេហទំព័រ Khmer SME**» ដើម្បីជួយដល់សហគ្រាសធុនតូច និងមធ្យម (SME) អភិវឌ្ឍគុណភាពផលិតផល ស្របតាមស្តង់ដារនៃកម្ពុជា។ គេហទំព័រ Khmer SME ជាថ្នាលព័ត៌មានឌីជីថល ផ្តល់ឱកាសឱ្យសហគ្រាសធុនតូច និងមធ្យមទាំងអស់ទទួលបាននូវព័ត៌មាននៅនឹងកន្លែងដូចជាផ្នែកច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តិ ការបណ្តុះបណ្តាលបច្ចេកទេស ការផ្ទេរ បច្ចេកវិទ្យា វិទ្យាសាស្ត្រ នវានុវត្តន៍ ហិរញ្ញប្បទាន ទីផ្សារ ការចាប់ផ្តើមអាជីវកម្មថ្មី ការលើកទឹកចិត្ត សម្រាប់ការធ្វើធុរកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ការប្រកួតប្រជែងមានលក្ខណៈជាយុទ្ធសាស្ត្រ និងប្រកបដោយបរិយាប័ន្ន។ ដូច្នេះ សហគ្រាសធុនតូច និងមធ្យម អាចទាញយកព័ត៌មានចាំបាច់ និងសំខាន់ៗ តាមតម្រូវការ ដើម្បីអភិវឌ្ឍផលិតផលឱ្យមានគុណភាព និងសុវត្ថិភាព ស្របតាមស្តង់ដារកម្ពុជា។

គេហទំព័រ Khmer SME បង្កើតឡើងក្រោមគម្រោងកិច្ចសហប្រតិបត្តិការរវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ GIZ។

រាជរដ្ឋាភិបាលកម្ពុជា បានលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម ជាវិស័យអាទិភាព ជួយស្តារសេដ្ឋកិច្ចជាតិឱ្យប្រសើរឡើងវិញ ដោយកំណត់នូវមុខផលិតផលមួយចំនួន ជាទំនិញយុទ្ធសាស្ត្រសម្រាប់ផ្គត់ផ្គង់តម្រូវការរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមរយៈផលិតផលទាំងអស់ ទាមទារចាំបាច់ត្រូវមានគុណភាព និងសុវត្ថិភាពដល់អ្នកប្រើប្រាស់។

ប្រធានសម្ព័ន្ធសហគ្រាសធុនតូច និងមធ្យម កម្ពុជាបានឱ្យដឹង «ជាការពិតគេហទំព័រ Khmer SME នឹងជួយយ៉ាងច្រើន ដល់សហគ្រាសធុនតូច និងមធ្យម

ដោយសារតែក្នុងគេហទំព័រមួយនេះ នឹងមានព័ត៌មានផ្សេងៗជាច្រើន ទាក់ទិននឹងវិស័យសហគ្រាសធុនតូច និងមធ្យម ដែលជាការផ្តល់ភាពងាយស្រួល ក្នុងការប្រកបអាជីវកម្ម គេហទំព័រនោះមានព័ត៌មានផ្សេងៗ ដូចជា ហិរញ្ញប្បទាន ទីផ្សារ ការចាប់ផ្តើមអាជីវកម្មថ្មី ការលើកទឹកចិត្ត សម្រាប់ការធ្វើធុរកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ការប្រកួតប្រជែងមានលក្ខណៈជាយុទ្ធសាស្ត្រជាដើម»។ កន្លងមកសម្ព័ន្ធសហគ្រាសធុនតូច និងមធ្យម កម្ពុជាបានរៀបចំកម្មវិធីផ្សេងៗ ដើម្បីឱ្យអ្នកនៅក្នុងវិស័យ SME មានការយល់ដឹងកាន់តែច្រើនជាក់ស្តែង មានការចុះបង្រៀនតាមបណ្តាខេត្តក្រុងនានា អំពីការប្រើប្រាស់ឥណទាន ចេះរៀបចំបញ្ជីស្នាមដើម្បីខ្ចីប្រាក់ពីធនាគារដើម្បីយកមកប្រកបអាជីវកម្ម៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnew ចេញផ្សាយថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១*

## ពាណិជ្ជកម្មកម្ពុជា-សហរដ្ឋអាមេរិក សម្រេចបានជិត ៦ ពាន់លានដុល្លារ នៅ៩ខែដំបូងឆ្នាំ២០២១



*ដោយ ខេមបូណ្ណមីស*

នៅអំឡុង៩ខែដំបូងក្នុងឆ្នាំ២០២១ ការនាំចេញរបស់កម្ពុជាទៅសហរដ្ឋអាមេរិកក សម្រេចបានជាង៥ពាន់លានដុល្លារ កើនឡើងជាង១០%បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ចំណែកការនាំចូលទំនិញពីសហរដ្ឋអាមេរិកមកកម្ពុជាវិញ មានជាង២រយលានដុល្លារ មានកំណើនជាង១៨%។

តួលេខនេះអាចបញ្ជាក់ថា វិបត្តិកូវីដ-១៩ មិនបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការធ្វើពាណិជ្ជកម្មរវាងកម្ពុជាជាមួយសហរដ្ឋអាមេរិកនោះទេ។ អ្នកនាំពាក្យក្រសួងពាណិជ្ជកម្មគូសបញ្ជាក់ថា ទំនិញនាំចេញទៅសហរដ្ឋអាមេរិកភាគច្រើនជាទំនិញបញ្ជាទិញមុនការផលិត។ មួយវិញទៀត ដោយសារក្រុមហ៊ុនមួយចំនួនបានបង្វែរការបញ្ជាទិញពីប្រទេសបង់ក្លាដែស ស្រីលង្កា និងមីយ៉ាម៉ាជាដើម មកបញ្ជាទិញទំនិញពីកម្ពុជាជំនួសវិញ បន្ទាប់ពីប្រទេសទាំងនោះជួបវិបត្តិនយោបាយ និងការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩។

អនុប្រធានសភាពាណិជ្ជកម្មកម្ពុជាបានបញ្ជាក់ថា កត្តាដែលធ្វើឱ្យការនាំចេញរបស់កម្ពុជាទៅសហរដ្ឋអាមេរិកនៅតែអាចរក្សាបាននូវកំណើន គឺដោយសារកម្ពុជាមានប្រព័ន្ធអនុគ្រោះពន្ធ GSP គួបផ្សំការបង្វែរការបញ្ជាទិញពីក្រុមហ៊ុនមួយចំនួនមកកម្ពុជា និងការគ្រប់គ្រងវិបត្តិកូវីដ-១៩បានល្អពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។
ទំនិញដែលកម្ពុជានាំចេញទៅកាន់ទីផ្សារនៅសហរដ្ឋអាមេរិកភាគច្រើនជាផលិតផលវាយនភណ្ឌសម្លៀកបំពាក់ កាបូប ស្បែកជើង កង់ និងផលិតផលសម្រាប់ការធ្វើដំណើរ ខណៈកម្ពុជានាំចូលពីសហរដ្ឋអាមេរិករួមមាន រថយន្ត ចំណីសត្វ និងគ្រឿងម៉ាស៊ីន។
ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-សហរដ្ឋអាមេរិក កាលពីឆ្នាំ២០២០ មានទំហំទឹកប្រាក់ជិត ៧ពាន់លានដុល្លារអាមេរិក កើនជិត១៨% បើធៀបនឹងឆ្នាំ២០១៩ ដែលមានទំហំទឹកប្រាក់ជិត៦ពាន់លានដុល្លារអាមេរិក៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ណមីសចេញផ្សាយថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១*

## គិតត្រឹម០៩ខែដំបូងនៃឆ្នាំ២០២១ ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងកូរ៉េខាងត្បូងធ្លាក់ចុះជាង១៨%



*ប្រភព៖ postkhmer, 2021 រូបភាព៖ យូសុះ អាប់ឌុលហាំស់ហ៊ីម*

យោងតាមទិន្នន័យរបស់សមាគមពាណិជ្ជកម្មអន្តរជាតិកូរ៉េ (Kita) បានបញ្ជាក់ថា ការនាំចេញ-នាំចូលទំនិញរវាងកម្ពុជា និងកូរ៉េខាងត្បូង ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១ មានតម្លៃសរុប ៧២០,៥២ លានដុល្លារ បានធ្លាក់ចុះ ១៨,៦%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ក្នុងនោះការនាំចេញទំនិញពីកម្ពុជាមានទឹកប្រាក់ ២៥៩,០៨ លានដុល្លារ បានធ្លាក់ចុះ ១៨,៥% និងការនាំចូលមកកម្ពុជាវិញមានទឹកប្រាក់ ៤៦១,៤៣ លានដុល្លារធ្លាក់ចុះ ១៨,៦៤%។

ថ្មីៗនេះ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា -កូរ៉េ (CKFTA) តាមប្រព័ន្ធអនឡាញជាមួយនឹងរដ្ឋមន្ត្រីពាណិជ្ជកម្មនៃសាធារណរដ្ឋកូរ៉េ។ តាមរយៈកិច្ចព្រមព្រៀងនេះ ប្រទេសកម្ពុជាសង្ឃឹមថានឹងអាចមានការនាំចេញផលិតផលខ្លួនទៅទីផ្សារក្នុងប្រទេសកូរ៉េកាន់តែច្រើន ជាពិសេសផលិតផលសម្លៀកបំពាក់ ស្បែកជើង កាបូប គ្រឿងបន្លាស់ ឧបករណ៍អេឡិចត្រូនិក កៅស៊ូ និងផលិតផលកសិកម្មជាដើម។

ក្នុងឆ្នាំ២០២១នេះ ជំងឺកូវីដ-១៩បានធ្វើឱ្យសង្វាក់ផលិតកម្មនៅកម្ពុជាជួបបញ្ហាជាច្រើន ខណៈដែលការនាំចូលផលិតផលពីកូរ៉េ មកកម្ពុជាក៏មិនសូវមានច្រើនដែរ។ ម្យ៉ាងទៀតផលិតផល ដែលផលិតនៅកម្ពុជាក្នុងពេលនេះក៏នៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់នៅកូរ៉េផងដែរ។

បន្ថែមពីនេះ CKFTA នឹងជួយធ្វើឱ្យការធ្វើពាណិជ្ជកម្មប្រទេសទាំង ២ កើនឡើងក្នុងពេលឆាប់ៗ ដោយមិនត្រឹមតែបានទាក់ទាញក្រុមហ៊ុនកូរ៉េចូលមកវិនិយោគនៅកម្ពុជាប៉ុណ្ណោះទេ សូម្បីតែក្រុមហ៊ុនបរទេសមួយចំនួនដែលផលិតសម្រាប់នាំចេញទៅទីផ្សារកូរ៉េ ក៏អាចនឹងមកបើករោងចក្រផលិតនៅកម្ពុជាដែរ។

អ្នកស្រាវជ្រាវសេដ្ឋកិច្ចអន្តរជាតិនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា និយាយថា វិបត្តិកូវីដ-១៩ បានធ្វើឱ្យសង្វាក់ផលិតកម្មមួយចំនួនធ្លាក់ចុះ ហើយតម្រូវការប្រើប្រាស់ផលិតផលមួយចំនួនក៏បានធ្លាក់ចុះផងដែរ ដោយប្រាក់ចំណូលរបស់ប្រជាជនធ្លាក់ចុះ ឯការវិនិយោគរបស់កូរ៉េនៅកម្ពុជា ដើម្បីផលិតសម្រាប់នាំចេញទៅកូរ៉េក៏នៅមានចំនួនតិចតួចនៅឡើយ៕ *ដោយ សេន ចន្ទូ*

*ប្រភព៖postkhmer.ចេញផ្សាយថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ២០២១*

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បញ្ជាក់ថា រុស្ស៊ី នឹងរៀបចំឱ្យពលរដ្ឋ មកលេងកម្ពុជា ក្នុងពេលឆាប់ៗនេះ

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានទទួលជួបពិភាក្សាការងារជាមួយលោកឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា នៅស្ថានទូតរុស្ស៊ី ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការទេសចរណ៍នៃប្រទេសទាំងពីរ។ ជំនួបនេះ សំដៅរៀបចំឱ្យមានការមកទស្សនារបស់ទេសចររុស្ស៊ីនៅកម្ពុជាឡើងវិញ ក្រោមយុទ្ធសាស្ត្របើកទេសចរវ៉ាក់សាំង ដែលរាជរដ្ឋាភិបាលបានប្រកាសនាពេលថ្មីៗនេះ ជាពិសេសការបើកតំបន់គោលដៅសុវត្ថិភាព ដូចជា ក្រុងព្រះសីហនុ កោះរុង

និងតំបន់តារាសាគរ ចាប់ពីថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ ២០២១ខាងមុខ ហើយតំបន់សៀមរាបអង្គរ ក្នុងអំឡុងខែមករា ឆ្នាំ២០២២ ខាងមុខ។ រុស្ស៊ីបានអះអាងថានឹងរៀបចំឱ្យពលរដ្ឋ មកលេងកម្ពុជាក្នុងពេលឆាប់ៗនេះ។ ភាគីទាំងពីរក៏បានឯកភាព ពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ និងដាក់ចុះនូវផែនការទទួលស្វាគមន៍ទេសចររុស្ស៊ីក្នុងក្របខណ្ឌយុទ្ធសាស្ត្រទេសចរវ៉ាក់សាំងរបស់កម្ពុជា ដូចជា ៖

ទី១៖ ការមកចុះសិក្សាពិនិត្យ ដោយក្រុមហ៊ុនទេសចរនិងបណ្តាញសារព័ត៌មានរុស្ស៊ី(Far Trip)ដើម្បីផ្សព្វផ្សាយការរៀបចំខ្លួនរួចស្រេចទទួលទេសចរអន្តរជាតិ។

ទី២៖ អញ្ជើញក្រុមហ៊ុនទេសចរណ៍រុស្ស៊ីចូលរួមការតាំងពិព័រណ៍ខ្នាតតូច នាឱកាសទិវាទេសចរណ៍អាស៊ាន ២០២២ នាខែមករា ដើម្បីជួបទំនាក់ទំនងធុរៈកិច្ចជាមួយក្រុមទេសចរណ៍កម្ពុជា និងក្នុងតំបន់ផងដែរ។

ទី៣៖ រៀបចំឱ្យមានសិក្ខាសាលាធុរៈកិច្ចទេសចរណ៍ប្រទេសទាំងពីរ។

ទី៤៖ បើកឱ្យមានការហោះហើរត្រង់ កម្ពុជា-រុស្ស៊ី។

ទី៥៖ ពិនិត្យរៀបចំកម្មវិធីឆ្នាំ២០២២ ជាឆ្នាំទេសចរណ៍និងវប្បធម៌កម្ពុជា-រុស្ស៊ី ដើម្បីអបអរសាទរខួបទី៦៦ នៃចំណងការទូតនៃប្រទេសទាំងពីរ។

ទី៦៖ ពិនិត្យរៀបចំបន្តកម្មវិធីការងាររួមកម្ពុជា-រុស្ស៊ីលើវិស័យទេសចរណ៍ តាមរយៈការចុះអនុស្សរណៈយោគយល់ លើកិច្ចសហប្រតិបត្តិការទេសចរណ៍កម្ពុជា-រុស្ស៊ី។

ទី៧៖ ពង្រីកកិច្ចសហប្រតិបត្តិការលើការផ្សព្វផ្សាយទេសចរណ៍ ការបង្កើតផលិតផលថ្មី ការវិនិយោគ និងការអភិវឌ្ឍធនធានមនុស្ស។

ទី៨៖ គាំទ្រការរៀបចំកីឡាស៊ីហ្គេម ២០២៣ (SEA GAMES 2023) នៅកម្ពុជា ជាពិសេសការរៀបចំកីឡាលើទឹក និងក្រោមទឹក។

ទី៩៖ គាំទ្រឱ្យមានការបណ្តុះបណ្តាលមគ្គុទ្ទេសក៍និយាយភាសារុស្ស៊ីតំបន់ឆ្នេរ។

ផ្អែកតាមទំនាក់ទំនងមិត្តភាពជាប្រវត្តិសាស្ត្រ និងសមិទ្ធិផលកន្លងមក កម្ពុជានឹងមានលទ្ធភាពទាក់ទាញទេសចររុស្ស៊ីបន្ថែមទៀត ដែលមុនវិបត្តិកូវីដ១៩ កំណើនពលរដ្ឋរុស្ស៊ីមកទស្សនានៅកម្ពុជា មានជាងកន្លះលាននាក់ ហើយចំនួននេះនឹងអាចកើនឡើងខ្ពស់ ដោយរុស្ស៊ីមានប្រជាជនជាង១៤៦លាននាក់។

ឯកអគ្គរដ្ឋទូតរុស្ស៊ី បានបង្ហាញអំពីការពេញចិត្តនៃកិច្ចសហប្រតិបត្តិការទេសចរណ៍ រវាងប្រទេសទាំងពីរកន្លងមក ក៏ដូចជាផែនការ និងយុទ្ធសាស្ត្រដាក់ចុះដោយរាជរដ្ឋាភិបាលនាពេលថ្មីៗ ជាការស្តារវិស័យទេសចរណ៍ មានដូចជា ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា អំឡុង និងក្រោយវិបត្តិកូវីដ១៩ ឆ្នាំ ២០២០-២០២៥ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី យុទ្ធសាស្ត្របើកទេសចរវ៉ាក់សាំង, វិធាននយោបាយលើការជំរុញទេសចរផ្ទៃក្នុង ការរៀបចំវិធានសុវត្ថិភាពទេសចរណ៍នានា(SOP)នានាជាដើម៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖SWIFTNEWS ចេញផ្សាយថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០២១*

## ការនាំចេញដូងប្រេងក្នុងឆ្នាំនេះធ្លាក់ចុះតិចតួច ប៉ុន្តែតម្លៃនៅតែខ្ពស់



ដោយ ខេមបូណ្ណមីស

ការនាំចេញដូងប្រេងទៅកាន់ទីផ្សារអន្តរជាតិ មានការថយចុះ ០,៤៨%។ កត្តាធ្វើឱ្យការនាំចេញដូងប្រេងក្នុងឆ្នាំនេះថយចុះ គឺខ្វះកម្លាំងដាំដុះ ហើយដើមដូងប្រេងមួយចំនួនក៏ផុតអាយុប្រមូលផល។ ឯកឧត្តម ឧកញ៉ាបណ្ឌិត ម៉ុង ឫទ្ធី អគ្គនាយកក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប និងជាអ្នកវិនិយោគលើដំណាំដូងប្រេង ដ៏ល្បីម្នាក់នៅកម្ពុជាបានមានប្រសាសន៍ថា ប្រទេសម៉ាឡេស៊ី និងឥណ្ឌា ជាទីផ្សារដូងប្រេងសំខាន់ និងមួយចំណែកទៀត គឺទីផ្សារក្នុងស្រុក។ តម្លៃដូងប្រេង នាឆ្នាំនេះប្រសើរជាងមុន។ នាខែតុលា ឆ្នាំ២០២១ ដូងប្រេង មានតម្លៃ ១ ពាន់ដុល្លារ ក្នុងមួយតោន។ បើសិនតម្លៃដូងប្រេងឡើងខ្ពស់ ដូចឆ្នាំនេះ គួបផ្សំមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងមានផ្ទៃដីធំទូលាយផងនោះ កសិករគួរដាំដូងប្រេង។ រយៈពេល ១០ខែ ឆ្នាំ២០២១ ការនាំចេញដូងប្រេង មានចំនួនប្រមាណ ៤១ ០០០តោន តិចជាង ឆ្នាំ ២០២០ ដែលបាននាំចេញដូងប្រេង បានជាង ៤៥ ០០០តោន។ ការដាំដូងប្រេង ទាមទារលក្ខខណ្ឌច្រើន ដូចជា កត្តាដី(ត្រូវការផ្ទៃដីធំ) ទឹកភ្លៀង បច្ចេកទេស និងចំណាយច្រើន។

ដូងប្រេង ត្រូវបានចាត់ទុកជាដំណាំកសិ-ឧស្សាហកម្ម និងជាវត្ថុធាតុដើមយ៉ាងសំខាន់ សម្រាប់ច្នៃជាចំណីអាហារ ថាមពល ឱសថ និងគ្រឿងសម្អាង ជាដើម។

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណ្ណមីសចេញផ្សាយថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ២០២១*

## កសិដ្ឋានចិញ្ចឹមគោយកទឹកដោះដ៏ធំនៅកម្ពុជា គ្រោងពង្រីកការផលិតទឹកដោះឱ្យបាន២ម៉ឺនលីត្រក្នុងមួយថ្ងៃ



ប្រភព ៖ freshnews

កសិដ្ឋានគិរីស្សួរគ៌ស្ថិតក្នុងចម្ងាយប្រមាណ៤០ គីឡូម៉ែត្រពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ២ បត់ចូលតាមផ្លូវទៅរមណីយដ្ឋានភ្នំម៉ៅ ប្រមាណមួយគីឡូម៉ែត្រនៅខាងស្តាំដៃ លើផ្ទៃដីសរុប៣០០ហិចតា ស្ថិតនៅជ្រលងភ្នំតាម៉ៅ ស្ថិតនៅក្នុងភូមិឱភាសាំង ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ។

កសិដ្ឋាននេះ បង្កើតឡើងដោយវិនិយោគិនខ្មែរសហការជាមួយជនជាតិអ៊ីស្រាអែលមានដើមទុនជិត ២០លានដុល្លារ និងប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយ របស់ប្រទេសអ៊ីស្រាអែល ទាំងការចិញ្ចឹម ការដាំស្មៅ និងការផលិតចំណី ដែលធ្វើឱ្យគោរបស់កសិដ្ឋាននេះ មានសមត្ថភាពអាចផលិតទឹកដោះគោបានច្រើន។

នាយកប្រតិបត្តិក្រុមហ៊ុនបានឱ្យដឹងថា កាលពីឆ្នាំ ២០២០ កសិដ្ឋានមួយនេះបាននាំយកគោ៥៥០ក្បាល ពីប្រទេសអូស្ត្រាលីមកចិញ្ចឹម។ មកទល់ពេលនេះ ការបង្កាត់គោ ដោយប្រើស្ពែមពីប្រទេសអ៊ីស្រ្តាអែល បានជាង ៨០០ក្បាលហើយ។ ផ្ទៃដីទំហំប្រមាណ ២០០

ហិកតា ប្រើសម្រាប់ដាំស្មៅប្រភេទផ្សេងៗ ដូចជាស្ដែទ្យូ (Stylo) មូមបាសា(Mombasa) និងពោត ផលិតជាចំណីគោ និងកន្លែងសម្រាប់ស្តុកទឹកប្រើប្រាស់។ ចំណែកផ្ទៃដី១០០ហិចតាទៀត ប្រើសម្រាប់ក្រោលគោ និងបម្រើឱ្យផលិតកម្មរបស់កសិដ្ឋាន។ បច្ចុប្បន្ននេះ កសិដ្ឋានគិរីស្សួរគ៌អាចផលិតទឹកដោះគោស្រស់បាន បរិមាណផលិតសរុបបានប្រមាណជាង ១ម៉ឺនលីត្រ ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ទាំងក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន។ ទឹកដោះគោស្រស់ ត្រូវបានផលិតឡើងតាមស្តង់ដារគុណភាពអនាម័យ និងមិនប្រើសារជាតុរក្សាទុកបានយូរនោះទេ។ នៅឆ្នាំ២០២២ខាងមុខនេះ កសិដ្ឋាននេះ បង្កើនគោដែលអាចយកទឹកដោះ ឱ្យបាន ១០០០ក្បាល ដើម្បីឈានទៅការផលិតទឹកដោះឱ្យបាន២ម៉ឺនលីត្រក្នុងថ្ងៃ។ ទឹកដោះគោគិរីស្សួរគ៌ បានឈានជើងចូលទីផ្សារ សាកល្បងដំបូងតាំងពីខែកញ្ញា ឆ្នាំ២០២០ និងចាប់ផ្ដើមដាក់លក់ជាផ្លូវការ នៅអំឡុងខែមីនា ឆ្នាំ២០២១ ដែលក្នុងរយៈពេល៩ខែនេះ ដណ្តើមបានចំណែកទីផ្សារប្រមាណ១០%ហើយ និងស្ថិតក្នុង Top 3 សម្រាប់ទីផ្សារទឹកដោះស្រស់ក្នុងប្រទេសកម្ពុជា។ បន្ថែមពីការផលិតទឹកដោះស្រស់ដាក់លក់នៅលើទីផ្សារកសិដ្ឋានមួយនេះ ក៏ផលិតយ៉ាអួរ និងប័រ ហើយនាពេលខាងមុខកសិដ្ឋាននេះ នឹងផលិតផលិតផលចេញពីទឹកដោះគោមួយចំនួនទៀតផងដែរ។

ទោះនាំបច្ចេកវិទ្យាពីប្រទេសអ៊ីស្រាអែល ប៉ុន្តែបុគ្គលិកបម្រើការក្នុងកសិដ្ឋាននេះស្ទើរតែ៩០% គឺបុគ្គលិកជនជាតិខ្មែរ ដែលជាប្រជាពលរដ្ឋនៅជុំវិញតំបន់ភ្នំតាម៉ៅ ដោយកសិដ្ឋាននេះមានបំណងចង់ផ្តល់នូវចំណេះដឹង និងបច្ចេកទេសថ្មីៗពីការចិញ្ចឹមគោ ការប្រេបាច់ទឹកដោះគោ ការដាំស្មៅ និងការរក្សាចំណីសម្រាប់ឱ្យគោស៊ីតាមបែបទំនើបដល់ពលរដ្ឋខ្មែរ។ ក្នុងចំណោមបុគ្គលិកជាង ១០០នាក់ ក្នុងនោះបុគ្គលិកបរទេសមានតែ៦នាក់ប៉ុណ្ណោះ។ លោកលើកទឹកចិត្តឱ្យប្រជាជនខ្មែរទាំងអស់គួរទទួលទានទឹកដោះស្រស់ឱ្យបានច្រើន ដើម្បីទទួលបានសុខភាពល្អ ឆ្អឹង រឹងមាំ និងកាត់បន្ថយស្ត្រេស៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍

### តារាងទី១ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិក លើមុខទំនិញនៅក្នុងខែសីហា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា៖ នៅក្នុងខែសីហា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុបចំនួន ៩៦៥,១លានដុល្លារ ដែលមានកំណើនប្រមាណជា ៣៩,១% បើធៀបនឹងខែកក្កដា ឆ្នាំ២០២១។

ជាក់ស្តែង ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់សរុប ៤៣លានដុល្លារនៅក្នុងខែសីហា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ២៩,៥% បើធៀបនឹងខែកក្កដា។ ការនាំចូលទំនិញសំខាន់ៗទាំងនេះរួមមាន៖ រថយន្តធ្វើដំណើរ ថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ផ្សិត ប្រេងសណ្តែក និងផលិតផលផ្សេងទៀត។

ស្របពេលនោះដែរ ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុប ៩២២,១ លានដុល្លារ នៅក្នុងខែសីហា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៣៩,៦% បើធៀបនឹងខែកក្កដា។ ការនាំចេញនេះ ភាគច្រើនជាប្រភេទទំនិញរួមមាន៖ ចង្កៀងនិងគ្រឿងបំភ្លឺអគ្គីសនី ការបូបយួរ ការបូបដាក់លុយ សំលៀកបំពាក់ និងផលិតផលផ្សេងៗទៀត៕

*ដោយ មិត្ត ចន្ទី*

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **614.5** | **572.7** | **782.1** | **685.7** | **650.3** | **534.9** | **693.9** | **965.1** |
| កំណើន % | | -6.8% | 36.6% | -12.3% | -5.2% | -17.8% | 29.7% | 39.1% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 | 38.1 | 28.8 | 33.2 | 43.0 |
| កំណើន % | | -1.8% | 17.4% | -24.8% | 29.6% | -24.4% | 15.3% | 29.5% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 | 612.2 | 506.1 | 660.7 | 922.1 |
| កំណើន % | | -7.1% | 37.7% | -11.7% | -6.7% | -17.3% | 30.5% | 39.6% |

*ប្រភព៖ការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យពាណិជ្ជកម្មសហរដ្ឋអាមេរិក*
*(គិតជាលានដុល្លារ)*

## តារាងទី២៖ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសប្រចាំខែសីហា នៅឆ្នាំ២០២១

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា នៅក្នុងខែសីហាឆ្នាំ២០២១នេះ រដ្ឋបាលថ្នាក់ជាតិ បានប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសសរុបចំនួន ១៥០,២៣ប៊ីលានរៀល ដែលមានការធ្លាក់ចុះប្រមាណជា៥,៤%បើធៀបនឹងខែកក្កដា នៃឆ្នាំដដែល។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូលបានសរុបចំនួន ១៤៦,៦៩ប៊ីលានរៀល នៅក្នុងខែសីហាឆ្នាំ២០២១នេះ ដែលមានការធ្លាក់ចុះប្រមាណជា ១,៤% បើធៀបនឹងខែកក្កដា ឆ្នាំ២០២១។

ស្របពេលពេលនោះដែរ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញបានសរុបចំនួន ៣,៥៤ប៊ីលានរៀលនៅក្នុងខែសីហាឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ២,៥% បើធៀបនឹងខែកក្កដា។*ដោយ៖ មិត្ត ចន្ទី*

| បរិយាយ(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
|---|---|---|---|---|---|---|---|---|
| **ចំណូលពន្ធលើ ពាណិជ្ជកម្មក្រៅប្រ ទេស** | **159.53** | **153.14** | **238.52** | **106.6** | **186.59** | **188.32** | **158.76** | **150.23** |
| កំណើន(%) | | -4.0% | 55.8% | -55.3% | 75.1% | 0.9% | -15.7% | -5.4% |
| ពន្ធ និងអាករលើការនាំចូល | 156.89 | 150.79 | 233.60 | 103.46 | 182.84 | 185.37 | 155.13 | 146.69 |
| កំណើន(%) | | -3.9% | 54.9% | -55.7% | 76.7% | 1.4% | -16.3% | -5.4% |
| ពន្ធ និងអាករលើការនាំចេញ | 2.64 | 2.35 | 4.92 | 3.12 | 3.75 | 2.95 | 3.63 | 3.54 |
| កំណើន(%) | | -11.0% | 109.4% | -36.6% | 20.2% | -21.3% | 23.1% | -2.5% |

*ប្រភព៖ តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែសីហាឆ្នាំ២០២១ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## មធ្យោបាយលើកទឹកចិត្តពន្ធនៅតាមបណ្តាប្រទេសសមាជិកអាស៊ានដើម្បីទាក់ទាញវិនិយោគ

| ប្រទេសសមាជិកអាស៊ាន | ព្រុយណេ | កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី | ហ្វីលីពីន | សិង្ហបុរី | ថៃ | វៀតណាម |
|---|---|---|---|---|---|---|---|---|---|
| អនុគ្រោះចំពោះពន្ធលើប្រាក់ចំណូល (Income Tax Exemption) | √ | √ | √ | √ | √ | √ | √ | √ | √ |
| ការកាត់បន្ថយអត្រាពន្ធ (Tax Rate Reduction) | | | √ | √ | √ | √ | √ | | √ |
| ការកាត់បន្ថយមូលដ្ឋាននៃការគិតពន្ធ (Tax Allowance) | √ | √ | √ | √ | √ | √ | √ | √ | √ |
| ការអនុគ្រោះលើពន្ធពាណិជ្ជកម្មក្រៅប្រទេស (Trade Tax Exemption) | √ | √ | √ | √ | √ | √ | √ | √ | √ |
| ឥណទានពន្ធ (Tax Credit) | | | | | | √ | | | √ |

*ប្រភព៖ AMRO-AREO, ២០២១*

យោងតាមការសិក្សារបស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (ASEAN+3 Macroeconomic Research Office) ដែលបានធ្វើឡើងកាលពីខែកញ្ញា ឆ្នាំ២០២១ បានបង្ហាញថា ប្រទេសដែលជាសមាជិកអាស៊ានបានប្រើប្រាស់មធ្យោបាយជាច្រើនដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) បង្កើនចំណូលរដ្ឋ និងដើម្បីធានាដល់ការអភិវឌ្ឍន៍ប្រកបដោយចិរភាពសម្រាប់ទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ។ មធ្យោបាយទាំងនោះរួមមាន៖ ផ្តល់ការអនុគ្រោះពន្ធលើប្រាក់ចំណូល អនុគ្រោះពន្ធពាណិជ្ជកម្មក្រៅប្រទេស កាត់បន្ថយអត្រាយកពន្ធ និងកាត់បន្ថយមូលដ្ឋាននៃការគិតពន្ធ ព្រមទាំងបានផ្តល់ឥណទានពន្ធដល់អ្នកបង់ពន្ធទៀតផង

(សូមមើលតារាងខាងលើ)។ យោងតាមតារាងខាងលើ ប្រទេសហ្វីលីពីន និងប្រទេសវៀតណាមបានផ្តល់ការអនុគ្រោះ និងការលើកទឹកចិត្តពន្ធច្រើនជាងគេ បើធៀបទៅនឹងប្រទេសផ្សេងទៀតដែលជាសមាជិកអាស៊ាន។ បន្ទាប់មកប្រទេសឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី និងសឹង្ហបុរីឈរនៅលំដាប់លេខរៀងទី២ នៃការអនុគ្រោះ និងលើកទឹកចិត្តពន្ធបន្ទាប់ពីប្រទេសហ្វីលីពីន និងវៀតណាម។ ចំណែកឯប្រទេសថៃ កម្ពុជា និងព្រុយណេផ្តល់ការអនុគ្រោះចំពោះពន្ធលើប្រាក់ចំណូល និងអនុគ្រោះលើពន្ធពាណិជ្ជកម្មក្រៅប្រទេស ព្រមទាំងបានកាត់បន្ថយមូលដ្ឋាននៃការគិតពន្ធ ដើម្បីទាក់ទាញអ្នកវិនិយោគ៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ AMRO ចេញផ្សាយខែកញ្ញា ឆ្នាំ២០២១*

## តម្រូវការប្រេងឥន្ធនៈនៅប្រទេសថៃ រងឥទ្ធិពលដោយសារវិបត្តិកូវីដ-១៩



*ប្រភព៖ Bangkok post រូបភាព៖ Somchai Poomlard*

ក្នុងរយៈពេលប្រាំបួនខែឆ្នាំ២០២១នេះការប្រើប្រាស់ប្រេងឥន្ធនៈនៅក្នុងប្រទេសថៃមានចំនួន ១៣០,៣ លានលីត្រក្នុងមួយថ្ងៃ បានធ្លាក់ចុះ ៥,២% ជាមធ្យម ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ ២០២០ ដែលធ្លាក់ចុះពី ១៣៧,១១ លានលីត្រ ដែលភាគច្រើនបណ្តាលមកពីរលកទីបីនៃការឆ្លងមេរោគកូវីដ-១៩។

យោងតាមនាយកដ្ឋានថាមពលបានបង្ហាញថា ការរឹតបន្តឹងការធ្វើដំណើរដើម្បីគ្រប់គ្រងការរីករាលដាល ជំងឺកូវីដ-១៩ក្នុងអំឡុងត្រីមាសទីពីរ និងទីបីគឺជាមូលហេតុចម្បងសម្រាប់ការធ្លាក់ចុះនៃតម្រូវការប្រេងឥន្ធនៈ។ ក្នុងនោះការធ្លាក់ចុះការប្រើប្រាស់ប្រេងឥន្ធនៈមានចំនួន ៤៤,៨% ប្រេងសាំងគ្មានជាតិគីមី(unleaded gasoline) ធ្លាក់ចុះ ១៦,៦% ហ្គាសដែលជាល្បាយនៃប្រេងសាំង និងអេតាណុលធ្លាក់ចុះ ៨,៧% ប្រេងម៉ាស៊ូត ៦,១% និងឧស្ម័នធម្មជាតិ ធ្លាក់ចុះ ១៩,៥% ក្នុងមួយថ្ងៃធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ។

ដោយឡែក តម្រូវការប្រេងឥន្ធនៈសម្រាប់យន្តហោះបានកើនឡើង ១៧,៤% ហ្គាស(LPG)ប្រើប្រាស់សម្រាប់ផលិតកម្ម និងគីមីឥន្ធនៈបានកើនឡើង ២,១% ប៉ុន្តែតម្រូវការសម្រាប់វិស័យដឹកជញ្ជូនបានធ្លាក់ចុះ ១៧,៨%។

ក្នុងរយៈពេល៩ខែក្នុង ឆ្នាំ២០២១ ប្រទេសថៃបាននាំចូលប្រេងឆៅ ចំនួន ៨៨៩ ៩៣៦ បារ៉ែលក្នុងមួយថ្ងៃ (BPD) និងប្រេងចម្រាញ់ថយចុះ ១%។

តម្លៃប្រេងឆៅ និងប្រេងចម្រាញ់ឡើងខ្ពស់នៅក្នុងទីផ្សារពិភពលោកបានធ្វើឱ្យតម្លៃនាំការនាំចូលកើនឡើង ៤៣,៦% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការនាំចេញប្រេងចម្រាញ់បានធ្លាក់ចុះ២,១ % ស្មើនឹង ១៩៥,៦៦៦(BPD) ជាមួយនឹងតម្លៃរបស់វាកើនឡើង ៤៩% ស្មើនឹង១៣,៩ ប៊ីលានបាតជាមធ្យមក្នុងមួយខែ៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ Bangkok post ចេញផ្សាយថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០២១*

## ពាណិជ្ជកម្មក្រៅប្រទេសនៅទីក្រុងហូជីមិញមានការងើបឡើងវិញយ៉ាងខ្លាំង




*ប្រភព៖ Viet Name News រូបភាព៖ Tuoitre*

សហគ្រាសពាណិជ្ជកម្មក្រៅប្រទេសដែលមានមូលដ្ឋាននៅទីក្រុងហូជីមិញបានបង្ហាញពីសញ្ញានៃការងើបឡើងវិញនៅក្នុងខែតុលា ដោយកើនឡើង ២៥,៨%ពីខែមុនដែលមានតម្លៃ ១១,៧ប៊ីលានដុល្លារ។

យោងតាមនាយកដ្ឋានគយបានបង្ហាញថា ការនាំចេញរបស់វៀតណាមកើនឡើង ៤,៧% ស្មើនឹង ៤,៤ប៊ីលានដុល្លារ និងការនាំចូលកើនឡើង ៤៨,៩% ស្មើនឹង ៧,៣ប៊ីលានដុល្លារ។ ក្នុងនោះប្រភេទទំនិញនៃការនាំចេញសំខាន់ៗរួមមាន កុំព្យូទ័រ គ្រឿងអេឡិចត្រូនិច ឧបករណ៍បច្ចេកវិទ្យា វាយនភ័ណ្ឌ ស្បែកជើង ជលផល និងផលិតផលកសិកម្ម។

ក្នុងរយៈពេល៩ខែដំបូងឆ្នាំ២០២១នេះ ការនាំចូលរបស់វៀតណាម មានតម្លៃ ២៤២,៦៥ប៊ីលានដុល្លារ កើនឡើង ៣០,៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ទីផ្សារនាំចេញផលិតផលរបស់វៀតណាម គឺសហរដ្ឋអាមេរិកនៅឈរលំដាប់ទី១ ដែលមានកំណើន ២៧,៦% ពីមួយឆ្នាំទៅមួយឆ្នាំ មានតម្លៃ ៦៩,៨ ប៊ីលានដុល្លារ បន្ទាប់មកទីផ្សារធំទី២ គឺប្រទេសចិនមានចំនួន៣៨,៥ ប៊ីលានដុល្លារ កើនឡើង១៨,៣% ក្រៅពីនេះផលិតផលវៀតណាមក៏បាននាំចេញទៅកាន់សហភាពអឺរ៉ុប និងអាសានផងដែរ។ *ដោយ មុំ ចិន្តា*

*ប្រភព៖ Viet Name News ចេញផ្សាយថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០២១*

## សសរស្តម្ភចំនួន៦របស់វៀតណាមដើម្បីស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ១៩




*(រូបភាព៖ ft.com)*

នាយករដ្ឋមន្ត្រីវៀតណាម បានប្រកាស ផែនការមេស្តារសេដ្ឋកិច្ចខ្លួន ដែលរួមមាន៖ ការគ្រប់គ្រងឱ្យបាននូវស្ថានភាពកូវីដ១៩ ជានាសន្តិសុខសង្គម បង្កើតការងារជួយស្តារអាជីវកម្មឡើងវិញ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កាត់បន្ថយនីតិវិធីរដ្ឋបាល និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយជាដើម។ សសរស្តម្ភធំៗចំនួន ៦ ដែលរដ្ឋាភិបាលនឹងត្រូវផ្តោតលើ ដើម្បីឈានទៅសម្រេចផែនការមេ រួមមាន ៖

សសរស្តម្ភទី១៖ វៀតណាម ត្រូវតែធ្វើឱ្យខ្សែសង្វាក់ផ្គត់ផ្គង់វិលត្រលប់មកដូចដើមវិញ ដើម្បីធានានូវចរន្តការផ្គត់ផ្គង់ទំនិញ និងសុវត្ថិភាព ក៏ដូចជាការដំណើរការយ៉ាងរលូននៃផលិតកម្មរបស់សហគ្រាស ស្របទៅតាមទិសដៅប្រក្រតីភាពថ្មី។

សសរស្តម្ភទី២៖ វៀតណាមនឹងជំរុញលើកកម្ពស់វិស័យកម្មន្តសាល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឱ្យកើនខ្ពស់ឡើងវិញ និងធ្វើឱ្យមានស្ថិរភាពនៃជីវភាពប្រជាពលរដ្ឋរបស់ខ្លួន។

សសរស្តម្ភទី៣៖ វៀតណាម ត្រូវការពង្រីកការវិនិយោគកាន់តែធំបន្ថែមទៀត ពិសេសនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងតំបន់ និងពិភពលោក, ការវិនិយោគថាមពលបៃតង និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលជាក្បាលម៉ាស៊ីនរុញកំណើនថ្មីសម្រាប់សេដ្ឋកិច្ច។

សសរស្តម្ភទី៤៖ វៀតណាមនឹងបន្តពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនថែមទៀត ដើម្បីដោះស្រាយការលំបាកដែលអាជីវកម្មកំពុងជួបប្រទះ រួមទាំងសហគ្រាសបរទេសដែលកំពុងវិនិយោគនៅក្នុងប្រទេសខ្លួន។

សសរស្តម្ភទី៥៖ វៀតណាម នឹងបន្តអភិវឌ្ឍការធ្វើកំណែទម្រង់ស្ថាប័នរដ្ឋ ដើម្បីឱ្យត្រូវនឹងស្តង់ដារពិភពលោក ហើយវាស្ថិតនៅក្នុងយុទ្ធសាស្ត្រដ៏សំខាន់មួយដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍នៅក្នុងទសវត្សរ៍ខាងមុខនេះ។

សសរស្តម្ភទី៦៖ ការអភិវឌ្ឍធនធានមនុស្ស ដើម្បីធានាឱ្យផលិតភាពការងារកាន់តែប្រសើរឡើង។

ក្រៅតែពីការផ្តោតលើសសរស្តម្ភទាំង៦នេះ នាយករដ្ឋមន្ត្រីវៀតណាម ក៏អំពាវនាវឱ្យវិនិយោគិនចូលរួមជាមួយរដ្ឋាភិបាល ដើម្បីឱ្យវិស័យផលិតកម្មត្រលប់មករកស្ថានភាពប្រសើរឡើងវិញនៅក្នុងតំបន់សួនឧស្សាហកម្ម ក៏ដូចជានៅតំបន់សេដ្ឋកិច្ចពិសេសជាដើម ដើម្បីការការពារសុវត្ថិភាពខ្សែសង្វាក់ផ្គត់ផ្គង់៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ២០២១*

## វៀតណាមរៀបចំអនុវត្តកាត់បន្ថយថ្លៃចុះបញ្ជីរថយន្ត ផលិតក្នុងស្រុក៥០%



*ដោយ postkhmer*

ក្រសួងហិរញ្ញវត្ថុវៀតណាម បានស្នើកាត់បន្ថយថ្លៃចុះឈ្មោះរថយន្តផលិតក្នុងស្រុកត្រឹម ៥០% រហូតដល់ខែឧសភាឆ្នាំ ២០២២ ដើម្បីបង្កើនការលក់ និងលើកទឹកចិត្តដល់ការងើបឡើងវិញក្នុងឧស្សាហកម្មរថយន្ត។ ការកាត់បន្ថយថ្លៃចុះបញ្ជីយានយន្តសម្រាប់ប្រភេទរថយន្តដំឡើងក្នុងប្រទេស នឹងជំរុញតម្រូវការរបស់អតិថិជន និងលើកស្ទួយការផលិតក្នុងប្រទេស និងសហគ្រាសដំឡើងរថយន្ត។ ការកាត់បន្ថយថ្លៃចុះបញ្ជីនេះអាចបន្ថយចំណូលពន្ធ ប៉ុន្តែប្រសិនបើចំនួននៃរថយន្តត្រូវបានលក់កើនខ្ពស់ នោះចំណូលសរុបអាចត្រូវបានរក្សា ឬអាចកើនខ្ពស់ជាងមុន។

រថយន្តផលិតក្នុងប្រទេសជាង ១០២ ៩០០ គ្រឿងត្រូវបានចុះបញ្ជីក្នុងឆមាសដំបូងកាលពីឆ្នាំមុន។ ចំនួននោះបានកើនឡើងទ្វេដងក្នុងឆមាសទី២ នៃឆ្នាំនោះ ពេលដែលថ្លៃសេវាត្រូវបានកាត់បន្ថយពាក់កណ្តាល តាមរបៀបស្រដៀងគ្នាទៅនឹងសំណើចុងក្រោយបំផុត។ ក្រសួងហិរញ្ញវត្ថុបានទទួលស្គាល់ការប្រឈម ខណៈពេលដែលអនុវត្តគោលនយោបាយគាំទ្រ ក្នុងវិបិត្តជំងឺកូវីដ ១៩។ សេចក្តីព្រួយបារម្ភគឺថា វៀតណាមប្រហែលមិនអនុវត្តពេញលេញចំពោះបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) របស់អង្គការពាណិជ្ជ

កម្មពិភពលោកនោះទេ ប្រសិនបើការផ្តល់ការអនុគ្រោះត្រូវបានផ្តល់ដល់ក្រុមហ៊ុនផលិតក្នុងស្រុកនោះ។

កាលពីថ្ងៃទី ២៥ ខែតុលា ក្រុមហ៊ុនរថយន្តបរទេសចំនួន ១១ Audi, Volkswagen, Subaru, Volvo, Jeep, និង Porsche ជាដើម បានអំពាវនាវឱ្យរដ្ឋាភិបាលវៀតណាម មិនគួរគ្រាន់តែផ្តល់ការលើកទឹកចិត្តដល់រថយន្តដែលផលិតក្នុងស្រុកទេ ដោយស្នើឱ្យមានការកាត់បន្ថយថ្លៃចុះបញ្ជីចំពោះរថយន្តដែលនាំចូលផងដែរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖postkhmer ចេញផ្សាយថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### រតនាគារសហរដ្ឋអាមេរិក គ្រោងនឹងធ្វើការខ្ចី ១,០២ទ្រីលានដុល្លារ សម្រាប់ត្រីមាសទី៤



*ប្រភព៖ Newsweek*

ក្នុងករណីដែលសភាសហរដ្ឋអាមេរិក សម្រេចតម្លើងពិដានបំណុលជាតិ នាយកដ្ឋានរតនាគារសហព័ន្ធ នឹងធ្វើការខ្ចីចំនួន ១,០២ទ្រីលានដុល្លារ សម្រាប់ត្រីមាសទីបួននេះ និងមានផែនការខ្ចី សម្រាប់ថ្ងៃខាងមុខ។ គួរបញ្ជាក់ថា ទំហំនៃការខ្ចីជាក់ស្តែង គឺផ្អែកលើសភា និងស្ថានភាពកំហិតបំណុល(Debt Limit)បច្ចុប្បន្ន។

កញ្ចប់កម្ចីថ្មីនេះ គឺមានទំហំធំបំផុត ចាប់តាំងពីរដ្ឋាភិបាល ចាប់ផ្តើមធ្វើការអនុម័តកញ្ចប់សង្គ្រោះសេដ្ឋកិច្ចដែលមានតម្លៃទ្រីលានដុល្លារ នៅនិទាឃរដូវឆ្នាំ២០២០។

គួរឱ្យកត់សម្គាល់ផងដែរថា យោងតាម រដ្ឋមន្ត្រីរតនាគារ លោក Jenet Yellen បានលើកឡើងថា ការតម្លើងកំហិតបំណុល(Debt Limit) ដែលសភាបានអនុម័តកាលពីខែតុលា ទៅលើទំហំទឹកប្រាក់កម្ចី ៤៨០ប៊ីលានដុល្លារ រដ្ឋាភិបាលអាចប្រើប្រាស់សម្រាប់ការទូទាត់ បានរហូតដល់ដើមខែធ្នូប៉ុណ្ណោះ។ បន្ថែមពីនេះ មន្ត្រីរតនាគារ ក៏បានរំពឹងថា នៅត្រីមាសទី១ ឆ្នាំក្រោយនេះ រតនាគារនឹងគ្រោងខ្ចីបន្ថែម ៤៧៦ប៊ីលានដុល្លារ៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Newsweek ចេញផ្សាយ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១*

### សេដ្ឋវិទូព្រមានថា សេដ្ឋកិច្ចចិនបានបង្ហាញសញ្ញាស្ថិរតាអតិផរណា(Stagflation)



*ប្រភព៖ CNBC ២០២១*

អ្នកសេដ្ឋកិច្ច បានគូសសម្គាល់ថា សេដ្ឋកិច្ចចិនបានបង្ហាញនូវរោគសញ្ញានៃស្ថិរតាផរណា(Stagflation—សកម្មភាពសេដ្ឋកិច្ចនៅទ្រឹង ស្របពេលដែលអតិផរណាកើនឡើងខ្ពស់) ដែលឆ្លុះបញ្ចាំងតាមរយៈ ការបន្តកើនឡើងនៃថ្លៃ ស្របពេលជាមួយនឹង ផលិតកម្មថមថយល្បឿន នេះបើយោងតាមទិន្នន័យផលិតចុងក្រោយ។

ទិន្នន័យស្ទង់មតិផ្លូវការ ដែលបានចេញនៅថ្ងៃទី៣១ ខែតុលា បង្ហាញថា សកម្មភាពរោងចក្រនៅប្រទេសចិន នៅខែតុលា បានធ្លាក់ចុះខ្លាំងជាងការរំពឹងទុក ដោយសន្ទស្សន៍ការគ្រប់គ្រងការទិញការផលិត(Manufac

turing Purchasing Managers' Index) មានពិន្ទុ ៤៩,២ ដែលទាបជាងកម្រិត ៥០(ដែលជាចំណុចញែកដាច់រវាងការធ្លាក់ចុះ និងការកើនឡើង)។ ចំណែកឯសន្ទស្សន៍ផលិតកម្ម ក៏បានធ្លាក់ចុះទៅកាន់កម្រិតទាបបំផុតផងដែរ(មិនគិតបញ្ចូលការធ្លាក់ចុះ ក្នុងកំឡុងវិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ២០០៨)។ ផ្ទុយទៅវិញ សន្ទស្សន៍តម្លៃទំនិញ បែរជាកើនឡើងទៅកម្រិតខ្ពស់បំផុត។ គួរបញ្ជាក់ថា សញ្ញាទាំងនេះ បានបង្ហាញថា សេដ្ឋកិច្ចចិន ទំនងជាកំពុងធ្លងកាត់ស្ថិរតាអតិផរណា។ បន្ថែមពីនេះ សញ្ញាព្រួយបារម្ភខាងមុខ គឺអតិផរណាបញ្ជូនពីតម្លៃវត្ថុធាតុដើម ទៅកាន់តម្លៃផលិតផល៕

***ដោយ ជា សិរីរតន៍***

*ប្រភព៖ CNBC ចេញផ្សាយ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១*

## តម្លៃបន្លែកើនខ្លាំងលើសតម្លៃសាច់ជ្រូក បង្កក្តីបារម្ភដល់ពលរដ្ឋចិន ស្របពេលតម្លៃស្បៀងអាហារពិភពលោកកើនឡើង




*ដោយ ខេមបូណ្ឌមីស*

ខេត្តសានតុង(Shandong)នៅភាគខាងជើងនៃប្រទេសចិន ជាខេត្តដាំដុះបន្លែបង្គាដ៏ធំរបស់ចិន។ នាចុងខែកញ្ញានិងដើមខែតុលានេះ ភ្លៀងធ្លាក់ខ្លាំងខុសពីធម្មតា ផលដំណាំត្រូវទឹកជន់លិចស្ទើរតែគ្មានអ្វីប្រមូលផល បានធ្វើឱ្យតម្លៃបន្លែនៅក្នុងខេត្ត បានហក់ឡើងខ្លាំង រហូតថ្លៃជាងសាច់សត្វ ដូចជាសាច់ជ្រូកទៅទៀត។ រដ្ឋាភិបាលទីក្រុងប៉េកាំងបានឱ្យដឹងថា តម្លៃបន្លែលក់ដុំជាមធ្យម បានកើនឡើងជិត៤០% ចាប់តាំងពីខែមុន។ អាជ្ញាធរបានគ្រោងនាំយកបន្លែពីខេត្តភាគខាងត្បូងមកវិញ តែត្រូវចំណាយថ្លៃដឹកជញ្ជូនខ្ពស់។ កំណើនថ្លៃនេះ ចំពេលកំពុងមានអតិផរណាក្នុងទីផ្សារចិន និងក៏គួបផ្សំតម្លៃស្បៀងអាហារពិភពលោកកំពុងឡើងថ្លៃដែរ។

បើយោងតាមអង្គការសហប្រជាជាតិ ស្បៀងអាហារ និងកសិកម្ម (FAO) តម្លៃស្បៀងអាហារ បានឡើងថ្លៃខ្លាំងគួរឱ្យព្រួយបារម្ភនៅទូទាំងពិភពលោក បើគិតក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ បានកើនឡើងប្រមាណជា៤០% ដែលជាកម្រិតឡើងខ្ពស់ខ្លាំងបំផុត បើគិតពីខែកញ្ញាឆ្នាំ ២០១១មក។ បញ្ហានេះ នឹងបង្កើនការលំបាកដល់ជីវភាពរបស់ប្រជាជន ជាពិសេសនៅតាមប្រទេសក្រីក្រ ហើយជាងនេះទៀត វាអាចរុញឱ្យកើតមានអស្ថិរភាព អសន្តិសុខ និងចលាចលក្នុងសង្គមផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១

- កំណើនអត្រាអតិផរណា កើនឡើងបន្ថែមទៀតដល់ 5.3% នៅក្នុងខែកញ្ញា ឆ្នាំ 2021
- កំណើនការវិនិយោគសរុបនៅក្នុងប្រទេសម៉ិកស៊ិក ឆ្នាំក្នុងខែកក្កដា ឆ្នាំ 2021

ថ្ងៃអង្គារ ទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មនៅប្រទេសអាឡឺម៉ង់ បានរួមតូច ក្នុងខែសីហា ឆ្នាំ 2021
- កំណើនអត្រាអតិផរណាប្រចាំឆ្នាំរបស់ម៉ិកស៊ិក បានកើនឡើងដល់ 6% ក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃពុធ ទី១០ ខែវិច្ឆិកា ឆ្នាំ២០២១

- កំណើនអត្រានីកម្មភាព តាមរដូវកាលនៅ កូរ៉េខាងត្បូងបានកើនដល់ 3% ក្នុងខែកញ្ញា ឆ្នាំ 2021
- អត្រានីកម្មភាព នៅក្នុងប្រទេសទួរគីមិនផ្លាស់ប្តូរ ក្នុងខែសីហា ឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី១១ ខែវិច្ឆិកា ឆ្នាំ២០២១

- នៅក្នុងឆ្នាំសារពើពន្ធ 2021 ឱនភាពថវិកា អាមេរិកបានឈានដល់ $2.772 trillion
- ឱនភាពពាណិជ្ជកម្មរបស់ចក្រភពអង់គ្លេសបានពង្រីក នៅក្នុងខែសីហានៃ 2021

ថ្ងៃសុក្រ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២១

- កំណើនអត្រាអតិផរណាប្រចាំឆ្នាំនៅប្រទេសអាហ្សង់ទីន ក្នុងខែកញ្ញា ឆ្នាំ 2021
- កំណើនអតិរេកពាណិជ្ជកម្មរបស់រុស្ស៊ី ឡើងដល់ 17,1 ពាន់លានដុល្លារក្នុងខែសីហា ឆ្នាំ 2021៕